# អត្ថន័យសិលាចារឹកសុវណ្ណភូមិ K.1419

ចាប់ពីចុងឆ្នាំ២០១៧មក មនុស្សម្នាជាច្រើនចាប់ផ្តើមចាប់អារម្មណ៍យ៉ាងខ្លាំងនឹងសិលាចារឹកមួយផ្ទាំងនៅវត្តគិរីស្តេចគង់ ដែលឃើញមានចារឹកពាក្យថា "**សុវណ្ណភូមិ**"។ សិលាចារឹកនោះ ព្រះសង្ឃ និងអ្នកស្រុករកឃើញនៅពេលធ្វើខឿនព្រះវិហារវត្ត និងបានយកទៅរក្សាក្នុងព្រះវិហាររហូតមក។ លុះមកដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ នាពេលលោកបណ្ឌិត **វង់ សុធារ៉ា** ចុះទៅស្រាវជ្រាវនៅទីនោះក៏ប្រទះឃើញសិលាចារឹកនេះ នឹងនាំឱ្យអ្នកស្រាវជ្រាវ និងមហាជននានាបានស្គាល់។ ចាប់តាំងពីពេលនោះមក សិលាចារឹកនេះត្រូវគេប្រសិទ្ធនាមថា «សិលាចារឹកសុវណ្ណភូមិ» រហូត[១]។ តើទីតាំងនោះមានសំណល់បុរាណវត្ថុអ្វីខ្លះ? តើសិលាចារឹកនោះមានអត្ថន័យដូចម្តេចខ្លះ?

**វត្តគិរីស្តេចគង់** ហៅ**វត្តបឹង** ដែលតាមឯកសារចាស់ៗបញ្ជាក់ថាមានឈ្មោះជា **អង្គប្រាសាទទន្លេយ៉ន** ស្ថិតនៅភូមិត្រពាំងខ្ទុំ ឃុំស្វាយចចិប ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ទីតាំងវត្តនេះ សាងសង់នៅលើទីទួលប្រាសាទបុរាណក្នុងសម័យមុនអង្គរ មានគូទឹកព័ទ្ធជុំវិញ។ ប្រាសាទនេះ គេរកឃើញថាមានការជួសជុលជាច្រើនដង ដោយឃើញមានវត្តមានឥដ្ឋបីប្រភេទដែលផលិតនៅសម័យមុនអង្គរ(ឥដ្ឋប្រាសាទដើម) សម័យអង្គរ និងសម័យក្រោយអង្គរ។ ចំណែកឯគ្រឹះប្រាសាទដែលបានរកឃើញវិញ អ្នកជំនាញសន្និដ្ឋានថាមានប្រាង្គបីស្ថិតនៅលើខឿនតែមួយ។ អ្នកជំនាញក្រសួងវប្បធម៌ បានប្រមូលសមុច្ច័យបុរាណវិទ្យាដែលបានមកពីកំណាយ និងមានស្រាប់នៅទីតាំងនោះ សរុបមានចំនួន៣៥ដុំ មានដូចជាសំណល់ផ្សេងនៃស្ថាបត្យកម្មប្រាសាទ ទម្រូបដិមា សន្ទឹកសីមា ទបង្ហូរទឹក និងសិលាចារឹកជាដើម។ អ្នកជំនាញសន្និដ្ឋានយ៉ាងដូច្នេះថា "ទីតាំងប្រាសាទនៅក្នុងវត្តគិរីស្តេចគង់ ត្រូវបានគេលួចគាស់បំផ្លាញ និងធ្វើព្រះវិហារពីលើអស់ប្រាង្គប្រាសាទពីរ និងពីលើខឿនអស់៣ភាគ៤រួចទៅហើយ។ ចំណែកឯក្រុមការងារធ្វើកំណាយបានរកឃើញខឿន និងគ្រឹះប្រាង្គប្រាសាទមួយផ្នែកដែលនៅសេសសល់ពីការសាងសង់ព្រះវិហារក្នុងឆ្នាំ២០០០"[២]។

---

[១] សូមអានបន្ថែម៖ វង់ សុធារ៉ា, ២០១៩: ១-២៧

[២] នាយកដ្ឋានបុរាណវិទ្យានិងបុរេប្រវត្តិវិទ្យា, ២០១៩

អត្ថបទដោយ៖ លោក ហ៊ុន ប៊ុនតេង

សិលាចារឹកនេះចារឹកដោយអក្សរខ្មែរសម័យមុនអង្គរ(បល្លវៈ) ចុះកាលបរិច្ឆេទនៅឆ្នាំ៥៥៥នៃមហាសករាជ ត្រូវនឹងឆ្នាំ៦៣៣គ.ស.។ តួអក្សរ និងសញ្ញាក្នុងសិលាចារឹកនេះប្រកបដោយលក្ខណៈសិល្បៈ វិចិត្រ ផ្ចិតផ្ចង់ និងសម្រិតសម្រាំង ដូចរាជសិលាចារឹកផ្លូវការឯទៀតៗដែរ។ របៀបចារសិលាចារឹកនេះដូចគ្នានឹងសិលាចារឹកភាគច្រើន ដែលចារនៅលើថ្មស្រទាប់ដែរ ពោលគឺប្រើដែកចារមុខមូល ដាប់ជាចំណុចខ្សែតាមទម្រង់តួអក្សរ[៣]។

អត្ថបទចារឹកចារជាកំណាព្យភាសាសំស្ក្រឹត មានចំនួន ២២ បន្ទាត់ ត្រូវជា ១១ ល្បះ តាក់តែងជាបទ ឧបជាតិ និងឥន្ទ្រវជ្រា។ បីល្បះដំបូងជាបទនមស្ការចំពោះព្រះឥសូរ ព្រះស្រីសានវិស្ណុ(ព្រះឥសូរ និង ព្រះវិស្ណុ) និងព្រះនារាយណ៍។ ល្បះទី៤ លើកសរសើរពីព្រះបាទឦសានវម៌្មទី១ ជាកំពូលរាជាធិរាជ។ ល្បះទី៥ ដល់ល្បះទី៨ បង្ហាញពីតួអង្គសំខាន់ជាអ្នកបម្រើរបស់ព្រះមហាក្សត្រ មានឈ្មោះថា "**ព្រៀឯត្ត**" និងកំណត់ត្រាអំពីការប្រតិស្ឋានប្រតិមាមួយចំនួន និងតង្វាយជាដីស្រែ គោ ក្របី។ ល្បះទី៩ ជាការដាក់បណ្ដាសាអ្នកបំផ្លាញ "ធម៌" ឬ "សមិទ្ធផល" ដែលបានសាងក្នុងសិលាចារឹកនេះ។ ពីរល្បះចុងក្រោយបង្ហាញពីកាលបរិច្ឆេទប្រតិស្ឋានប្រតិមាព្រះហរក្រឹស្ណៈ (ព្រះឥសូរ និងព្រះនារាយណ៍) ដោយសាសនិកឈ្មោះ "**ព្រៀឯត្ត**" ពោលគឺនៅថ្ងៃ១រោច ខែចេត្រ(មីនា-មេសា) ឆ្នាំ៥៥៥ នៃមហាសករាជ (៦៣៣ គ.ស.)[៤]។

ល្បះទី៤ គឺជាល្បះសំខាន់ជាងគេនៅក្នុងសិលាចារឹកនេះ ដែលនាំឱ្យអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ បើកកិច្ចពិភាក្សាថាពាក្យ "**សុវណ្ណភូមិ**" ក្នុងសិលាចារឹកនេះសំដៅដល់ដែនដីសុវណ្ណភូមិពិតប្រាកដឬទេ។ ខាងក្រោមនេះជាអត្ថបទដកស្រង់ល្បះទី៤ ៖

[...] ៧- សមុទ្របយ៌្យន្តសុវណ៌្ណភូមិ ប្ឫថ្វែករាជេន្ទ្របរាក្រមគ្រីះ

៨- សមស្តសាមន្តគិរោធ្ឫតាជ្ញ គ្រ្វីគានវម៌្មាជយតិក្សិតីគះ //

បណ្ឌិត **ឆោម គន្ធា** បង្ហាញថាល្បះនេះមានលទ្ធភាពបកប្រែបាន៦យ៉ាង[៥]៖

[៣] សូមអានបន្ថែម៖ ហ៊ុន ឈុនតេង, ២០១៩: ២៨-៣២

[៤] ឆោម គន្ធា, ២០១៩: ៣៥

[៥] ឆោម គន្ធា, ២០១៩: ៣៨

សូមព្រះបាទស្រីឦសានវម៌្ម(ទី១) មានជោគមានជ័យ! ពួកស្តេចនគរចំណុះ នាំគ្នាទូលព្រះរាជបញ្ជាព្រះអង្គលើសិរសាតែរៀងខ្លួន។

ក- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភោគ ដូចព្រះឥន្ទ្រជាស្តេចឯក នៅលើផ្ទៃនៃផែនដីមាស ទៅទល់នឹងសមុទ្រ។

ខ- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភោគ ដូចស្តេចចក្រពត្តិ(ស្តេចនៃស្តេចទាំងឡាយ) ជាឯកនៅលើផ្ទៃនៃផែនដីមាស ទៅទល់នឹងសមុទ្រ។

គ- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភោគនៃស្តេចចក្រពត្តិ ជាឯកនៅលើផ្ទៃដីមានព័ណ៌ស្រស់បំព្រង ទៅទល់នឹងសមុទ្រ។

ឃ- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភោគនៃស្តេចចក្រពត្តិ ជាឯកនៅលើផ្ទៃដី(ឈ្មោះថា)សុវណ្ណ ទៅទល់នឹងសមុទ្រ។

ង- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភោគនៃស្តេចចក្រពត្តិ ជាឯកនៅលើដែន(ដីឈ្មោះថា)សុវណ្ណភូមិ ទៅទល់នឹងសមុទ្រ។

ច- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភោគនៃស្តេចចក្រពត្តិ ជាឯកនៅលើផ្ទៃ(ដីនៅក្នុងដែន)សុវណ្ណភូមិ ទៅទល់នឹងសមុទ្រ។



*ផ្តែរចនាបថសំបូរព្រៃគុក រក្សាទុកក្នុងព្រះវិហារ (ខែមករា ឆ្នាំ២០១៨)*



*សិលាចារឹក* K.1419 *មានពាក្យ* ***សុវណ្ណភូមិ*** *(ខែមករា ឆ្នាំ២០១៨)*

*អត្ថបទដោយៈ លោក ហ៊ុន ប៊ុនតេង*


គូទឹកប្រាសាទដែលជីកស្តានិងពង្រីក
(ខែមករា ឆ្នាំ២០១៨)


ខឿនប្រាសាទ ធ្វើកំណាយដោយក្រសួងវប្បធម៌
និងវិចិត្រសិល្បៈ (ខែកក្កដា ឆ្នាំ២០២០)


សំណល់សម្ភារៈសំណង់ប្រាសាទនិងសិលា
ចារឹក (ខែកក្កដា ឆ្នាំ២០២០)


សំណល់សម្ភារៈសំណង់ប្រាសាទនិងសិលា
ចារឹក (ខែកក្កដា ឆ្នាំ២០២០)


ទីតម្កល់សិលាចារឹកចម្លងថ្មី នៅ
ខាងជើងព្រះវិហារ
(ខែកក្កដា ឆ្នាំ២០២០)

KHMER CIVILIZATION

អត្ថបទដោយ៖ លោក ហ៊ុន ប៊ុនតេង

## ឯកសារយោង


ឆោម គន្ធា

២០១៩. "សិលាចារឹកវត្តគិរីស្តេចគង់K.1419៖ សេចក្តីបកប្រែនិងសេចក្តីអត្ថាធិប្បាយ", កម្ពុជសុរិយា ឆ្នាំទី៦៦ លេខ៤(លេខពិសេស), ទំព័រ៣៩-៥៤, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

នាយកដ្ឋានបុរាណវិទ្យានិងបុរេប្រវត្តិវិទ្យា

២០១៩. របាយការណ៍ស្តីពីការធ្វើកំណាយបង្ការនៅវត្តគិរីស្តេចគង់, ភ្នំពេញ។

វង់ សុធារ៉ា

២០១៩. "សិលាចារឹកវត្តគិរីស្តេចគង់ K.1419៖ ប្រវត្តិសិលាចារឹក និងស្ថាននាមសុវណ្ណភូមិ", កម្ពុជសុរិយា ឆ្នាំទី៦៦ លេខ៤(លេខពិសេស), ទំព័រ១-២៧, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

ហ៊ុន ឈុនតេង

២០១៩. "សិលាចារឹកវត្តគិរីស្តេចគង់ K.1419៖ អំណានអត្ថបទ និងលក្ខណៈតួអក្សរចារឹក", កម្ពុជសុរិយា ឆ្នាំទី៦៦ លេខ៤(លេខពិសេស), ទំព័រ២៨-៣៤, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។